# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១៤-៦-២០១៤ -ព្រះរាជក្រម នស/រកម/០៦១៤/០១១ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ៥៧៤០

១៤-៦-២០១៤ -ព្រះរាជក្រម នស/រកម/០៦១៤/០១២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើលិខិតសន្យាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស៊ីធីលុម អេសអេ សម្រាប់គម្រោងវិនិយោគសាងសង់ ផ្ទេរ និងប្រតិបត្តិការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺសាធារណៈ នៅរាជធានីភ្នំពេញ ៥៧៧០


### ២~ព្រះរាជក្រឹត្យ


៣១-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៦៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្មដល់អ្នកស្រី **ត្រឹង ចាងថាញ់ស៊ួន** (TRAN CHANG THANH XUAN) ជនជាតិវៀតណាម សញ្ជាតិកាណាដា កើតនៅខេត្តគៀនយ៉ាង សាធារណរដ្ឋសង្គមនិយមវៀតណាម ៥៧៧៦

៣១-៥-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៥១៤/៦៧០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ញាតូបនីយកម្មដល់លោក **ចាង ស៊ឺជៀន** (ZHANG ZIJIAN) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ចេគ ចាង** ( JACK ZHANG) ៥៧៧៧

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧១ ស្តីពី ការកែសម្រួលមាត្រា ២ មាត្រា ៤ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ៥៧៧៨

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧២ ស្តីពីការតែងតាំង និងផ្តល់ឋានៈជូនឯកឧត្តមចំនួន ០២ រូប ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ៥៧៨១

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧៣ ស្តីពី ការប្តូរ និងតម្លើង ប្រភេទក្របខ័ណ្ឌ លោក ព្រំ សំអុល ពីឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជាករណីពិសេស នៅអង្គភាពប្រឆាំងអំពើពុករលួយ ៥៧៨២

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧៤ ស្តីពី ការប្រគល់ភារកិច្ចជូនឯកឧត្តម **សេងហុង ស្ទុជាតិខេមរ៉ូ** ឱ្យបំពេញមុខងារជាអគ្គនាយក នៃអគ្គនាយកដ្ឋានលំនៅដ្ឋាន នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៥៧៨៣

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧៥ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ០២ រូប របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ៥៧៨៤

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ជូននាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥៧៨៥

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧៧ ស្តីពី ការតែងតាំងឯកឧត្តមឧត្តមសេនីយ៍ទោ **គឹ ដារ៉ា** ជា ទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៥៧៨៦

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧៨ ស្តីពី ការតែងតាំងលោក **យ៉ុន ម៉ុនលី** ជា ឧកញ៉ា ៥៧៨៧

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៧៩ ស្តីពី ការប្តូរប្រភេទក្របខ័ណ្ឌតាមលទ្ធផលប្រឡងប្រជែងផ្ទៃក្នុង ជូនមន្ត្រីរាជការ ១១៤ រូប របស់ក្រសួងផែនការ ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៥៧៨៨

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ និងអស់លោក ចំនួន ០៤ រូប ៥៧៩៣

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨១ ស្តីពី ការតែងតាំងលោក **គេង ឡាយ** ជា ឧកញ៉ា ៥៧៩៤

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨២ ស្តីពី ការតែងតាំងឯកឧត្តម **ហ៊ាច ឈុនហេង** ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ៥៧៩៥

០៣-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ អស់លោក និង លោកស្រី ចំនួន ១៧ រូប ៥៧៩៦

០៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨៤ ស្តីពី ការតែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប នៃក្រសួងពាណិជ្ជកម្ម ៥៧៩៧

០៤-៦-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៦១៤/៦៨៥ ស្តីពី ការតែងតាំងទីប្រឹក្សាក្រសួងរ៉ែ និងថាមពល ចំនួន ០២ រូប មានឋានៈស្មើ អគ្គនាយក ៥៧៩៨

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

១៣-៦-២០១៤ -អនុក្រឹត្យលេខ ២០២ អនក្រ.បក ស្តីពី ការកំណត់សមមូលឋានន្តរស័ក្តិមន្ត្រីពន្ធនាគារជាមួយនឹងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ៥៧៩៩

១៣-៦-២០១៤ -អនុក្រឹត្យលេខ ២០៣ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ២ ថ្មី (ពីរ) នៃអនុក្រឹត្យលេខ ១៧៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា ២ ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៨ ស្តីពី ការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ៥៨០៧

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៨១០

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៨១២

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៨១៤

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥៨១៦

១៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៨១៨

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៨២០

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨២១

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨១ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥៨២៣

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨២៤

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៨២៥

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨២៧

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៨៣០

២៦-៥-២០១៤ -អនុក្រឹត្យលេខ ៥៨៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨៣៦

## ២. សារាចរ

២០-៦-២០១៤ -សារាចរលេខ ០៥ សរ ស្តីពី ការប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា លើកទី ៧ ៥៨៣៩

២៣-៦-២០១៤ -សារាចរលេខ ០៦ សរ ស្តីពី ការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ០១ ខែតុលា ៥៨៤១

## ៣. សារាចរណែនាំ

១២-៦-២០១៤ -សារាចរណែនាំលេខ ០៥ សរណន ស្តីពី ការចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ និងដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះករុណា ព្រះបរមរតនកោដ្ឋ" ៥៨៤៤

# III. ការងារបណ្តាក្រសួង

## ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-៦-២០១៤ -ប្រកាសលេខ ៦៣៨ សហវ.ប្រក.អពដ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ៥៨៤៦

១៩-៦-២០១៤ -ប្រកាសលេខ ៦៤៩ សហវ.ប្រក ស្តីពី ការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥៨៤៩

១៩-៦-២០១៤ -សេចក្តីសម្រេចលេខ ០២៣ សហវ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥៨៥៣

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

០៦-៥-២០១៤ -ប្រកាសលេខ ៣៨៧ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូនីខន(ខេមបូឌា) វីគ្រីអេសិន ប្រូដាក់ បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៥៨៥៦

០៨-៥-២០១៤ -ប្រកាសលេខ ៣៩២ ឧស.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ីសធើន អង្គរអ៊ីនវេសម៉ិន បង្កើតរោងចក្រផលិត ប្រដាប់ព្យួរសម្លៀកបំពាក់ (ពីប្លាស្ទិក), ប្រដាប់ព្យួរសម្លៀកបំពាក់ (ពីដែក) ៥៨៦០

# ព្រះរាជក្រម

នស/រកម/០៦១៤/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ
## និងអភ័យឯកសិទ្ធិនៃសមាគមប្រជាជាតិ
## អាស៊ីអាគ្នេយ៍

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលបានចុះហត្ថលេខា នៅចាអាម-ហួហ៊ីន ព្រះរាជាណាចក្រថៃ នាថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០០៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៤

នស/រកម.០៦១៤.០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**ហត្ថលេខា**

**ហោ ណាំហុង**

លេខៈ ៧៦៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

*(បកប្រែក្រៅផ្លូវការ)*

# កិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

រដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេ ដារូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ារ សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលបន្ទាប់តទៅ និយាយសំដៅជារួមថា "រដ្ឋសមាជិក" ឬសំដៅជាឯកត្តរដ្ឋថា "រដ្ឋសមាជិកនីមួយៗ"។

ដោយរំលឹកដល់ ធម្មនុញ្ញអាស៊ាន ដែលត្រូវបានចុះហត្ថលេខានៅប្រទេសសឹង្ហបុរី ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០០៧

ដោយទទួលស្គាល់ថា មាត្រា៣នៃធម្មនុញ្ញអាស៊ាន ផ្តល់អំណាចឱ្យអាស៊ាន ដែលជាអង្គភាពអន្តររដ្ឋាភិបាល មានបុគ្គលភាពគតិយុត្ត និង

ដោយទទួលស្គាល់បន្ថែមទៀតថា មាត្រា១៧ មាត្រា១៨ និងមាត្រា១៩ នៃធម្មនុញ្ញអាស៊ាន ផ្តល់ឱ្យនូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដល់អាស៊ាន នៅលើទឹកដីនៃរដ្ឋសមាជិករបស់ខ្លួន ក្នុងពេលចាំបាច់ ដើម្បីបំពេញគោលបំណងរបស់ខ្លួន ផ្តល់ដល់អគ្គលេខាធិការអាស៊ាន និងបុគ្គលិកនៃលេខាធិការដ្ឋានអាស៊ាន ក្នុងពេលចាំបាច់សម្រាប់បំពេញមុខងាររបស់ខ្លួនដោយឯករាជ្យ និងដល់តំណាងអចិន្ត្រៃយ៍របស់រដ្ឋសមាជិកប្រចាំអាស៊ាន ព្រមទាំងមន្ត្រីរបស់រដ្ឋសមាជិក និងមន្ត្រីដែលកំពុងបំពេញភារកិច្ចអាស៊ាន ក្នុងពេលចាំបាច់សម្រាប់បំពេញមុខងាររបស់ខ្លួន។

បានឯកភាពដូចខាងក្រោម៖

## មាត្រា ១
## និយមន័យ

តាមកិច្ចព្រមព្រៀងនេះ ពាក្យ៖

១. "រដ្ឋសមាជិកម្ចាស់ផ្ទះ" មានន័យថា រដ្ឋសមាជិកណាមួយ ដែលលេខាធិការដ្ឋានអាស៊ាន ឬស្ថាប័នអាស៊ាននានាតាំងនៅ។

២. "សមាជិកនៃក្រុមបុគ្គលិករដ្ឋបាល និងបច្ចេកទេស" មានន័យថា សមាជិកនៃបុគ្គលិករបស់ស្ថានបេសកកម្មអចិន្ត្រៃយ៍ ដែលបំពេញការងារក្នុងកិច្ចការរដ្ឋបាល និងបច្ចេកទេសនៃស្ថានបេសកកម្មអចិន្ត្រៃយ៍នោះ។

៣. "សមាជិកនៃក្រុមបុគ្គលិកសេវាកម្ម" មានន័យថា សមាជិកនៃបុគ្គលិករបស់ស្ថានបេសកកម្មអចិន្ត្រៃយ៍ ដែលបំពេញការងារក្នុងវិស័យសេវាកម្មនៅក្នុងស្រុកនៃស្ថានបេសកកម្មអចិន្ត្រៃយ៍នោះតាំងនៅ។

៤. "សកម្មភាពផ្លូវការរបស់អាស៊ាន" មានន័យថា កិច្ចប្រជុំ សន្និសីទ និងសកម្មភាពនានារបស់អង្គភាពអាស៊ាន យោងទៅតាមជំពូកទី៤ នៃធម្មនុញ្ញអាស៊ាន ក្នុងការបំពេញភារកិច្ច និងមុខងាររបស់ខ្លួន។

៥. "មន្ត្រីនៃរដ្ឋសមាជិក" មានន័យថា បុគ្គលណាដែលត្រូវបានតែងតាំងយ៉ាងត្រឹមត្រូវដោយរដ្ឋសមាជិកណាមួយឱ្យបំពេញការងារជាលក្ខណៈផ្លូវការ និងចូលរួមក្នុងសកម្មភាពផ្លូវការរបស់អាស៊ាន ក្នុងសមត្ថភាពជាតំណាងឱ្យរដ្ឋសមាជិកនោះ ឬបុគ្គលណាដែលត្រូវបានតែងតាំងដោយអង្គភាពសមស្របរបស់អាស៊ានណាមួយ យោងទៅតាមជំពូកទី ៤ នៃធម្មនុញ្ញអាស៊ាន ខណៈដែលតំណាងរបស់ខ្លួននៅក្នុងរដ្ឋសមាជិកនោះ៖

(ក) កាន់លិខិតឆ្លងដែនការទូត ឬលិខិតឆ្លងដែនផ្លូវការ។ ឬ

(ខ) បានជូនព័ត៌មានដល់រដ្ឋសមាជិកម្ចាស់ផ្ទះតាមផ្លូវការទូត ឬទៅភ្នាក់ងារដែលបញ្ញត្តិដោយរដ្ឋសមាជិកម្ចាស់ផ្ទះថា ជាបុគ្គលដែលត្រូវទទួលបាននូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិតាមកិច្ចព្រមព្រៀងនេះហើយដែលរដ្ឋសមាជិកម្ចាស់ផ្ទះអាចបដិសេធអំពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនេះបាន ដោយអនុលោមតាមបញ្ញត្តិរបស់ធម្មនុញ្ញអាស៊ាន និងគោលការណ៍ច្បាប់អន្តរជាតិពាក់ព័ន្ធដទៃទៀត។

៦. "មន្ត្រីកំពុងបំពេញភារកិច្ចអាស៊ាន" មានន័យថា បុគ្គលណាដែលបានតែងតាំងដោយរដ្ឋសមាជិកនីមួយៗ ជាសមាជិកនៃស្ថានបេសកកម្មអចិន្ត្រៃយ៍ មានឋានៈការទូត និងមានភារកិច្ចទទួលខុសត្រូវទ្រទ្រង់មុខនាទីរបស់ស្ថានបេសកកម្មអចិន្ត្រៃយ៍។

៧. "ស្ថានបេសកកម្មអចិន្ត្រៃយ៍" មានន័យថា ស្ថានបេសកកម្មរបស់រដ្ឋសមាជិកប្រចាំអាស៊ាន ដែលមានទីតាំងស្ថិតនៅទីក្រុងហ្សាការតា និងដឹកនាំដោយតំណាងអចិន្ត្រៃយ៍នៃរដ្ឋសមាជិកនោះ។

៨. "តំណាងអចិន្ត្រៃយ៍" មានន័យថា បុគ្គលណាដែលបានតែងតាំងជាតំណាងអចិន្ត្រៃយ៍ប្រចាំអាស៊ាន មានឋានៈជាឯកអគ្គរាជទូត/រដ្ឋទូត ដោយរដ្ឋសមាជិកនីមួយៗ ឱ្យប្រចាំនៅទីក្រុងហ្សាការតា ហើយមានភារកិច្ចបំពេញតួនាទីក្នុងសមត្ថភាពនោះ។

៩. "ទីស្នាក់ការរបស់អាស៊ាន" មានន័យថា អាគារ ឬផ្នែកនៃអាគារ និងទីលានជាប់នឹងអាគារ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ដែលប្រើប្រាស់សម្រាប់គោលដៅរបស់អាស៊ាន រួមទាំងនិវេសនដ្ឋានរបស់អគ្គលេខាធិការអាស៊ាន។

១០. "ទីស្នាក់ការរបស់ស្ថានបេសកកម្មអចិន្ត្រៃយ៍" មានន័យថា អាគារ ឬផ្នែកនៃអាគារ និងទីលានជាប់នឹងអាគារ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ដែលប្រើប្រាស់សម្រាប់គោលដៅរបស់ស្ថានបេសកកម្មអចិន្ត្រៃយ៍ រួមទាំងនិវេសនដ្ឋានរបស់តំណាងអចិន្ត្រៃយ៍។

១១. "អ្នកបម្រើឯកជន" មានន័យថា បុគ្គលណា ដែលបម្រើការនៅក្នុងលំនៅដ្ឋានរបស់សមាជិកណាមួយ នៃស្ថានបេសកកម្មអចិន្ត្រៃយ៍ ហើយដែលមិនមែនជានិយោជិករបស់រដ្ឋសមាជិកដែលជាក់ទូត។

១២. "ទ្រព្យសម្បត្តិ និងចលនទ្រព្យរបស់អាស៊ាន" មានន័យថា ទ្រព្យសម្បត្តិទាំងអស់ មិនថាជាអចលនវត្ថុ ឬចលនវត្ថុដែលជាកម្មសិទ្ធិរបស់អាស៊ាន ទោះជាស្ថិតនៅទីណា និងកាន់កាប់ដោយអ្នកណាក៏ដោយ។

១៣. "អនុសញ្ញាទីក្រុងវីយែន" មានន័យថា អនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត។

## មាត្រា ២
## បុគ្គលភាពគតិយុត្ត

១. អាស្រ័យដោយបុគ្គលភាពគតិយុត្ត អាស៊ានមានសមត្ថភាព ដូចខាងក្រោម នៅក្រោមច្បាប់ផ្ទៃក្នុងរបស់រដ្ឋសមាជិក៖

(ក) ចូលជាភាគីនៃកិច្ចសន្យា។

(ខ) ទិញ និងលក់ចលនទ្រព្យ និងអចលនទ្រព្យ។ និង

(គ) ដាក់ពាក្យបណ្តឹង និងការពារខ្លួនតាមនីតិវិធីតាមផ្លូវច្បាប់។

ក្នុងការអនុវត្តន៍សមត្ថកិច្ចទាំងនេះ អាស៊ានត្រូវតំណាងដោយអគ្គលេខាធិការអាស៊ាន អគ្គលេខាធិការរង ឬសមាជិកណាមួយនៃបុគ្គលិករបស់លេខាធិការដ្ឋានអាស៊ាន ដែលទទួលបានសិទ្ធិផ្តល់ដោយអគ្គលេខាធិការអាស៊ាន។

២. ក្នុងការអនុវត្តន៍សមត្ថកិច្ចរបស់ខ្លួនតាមច្បាប់អន្តរជាតិ ក្នុងនោះរួមមាន អំណាចចុះហត្ថលេខាកិច្ចព្រមព្រៀងតាមមាត្រា៤១ (៧) នៃធម្មនុញ្ញអាស៊ាន អាស៊ានត្រូវបំពេញមុខងារតាមរយៈតំណាងរបស់ខ្លួន ដែលទទួលបានសិទ្ធិផ្តល់ដោយរដ្ឋសមាជិក។

## មាត្រា ៣
## អាស៊ាន

១. អាស៊ាន និងទ្រព្យសម្បត្តិ និងចលនទ្រព្យរបស់អាស៊ាន ត្រូវទទួលបានអភ័យឯកសិទ្ធិរួចពីដំណើរការតាមផ្លូវតុលាការតាមគ្រប់រូបភាព លើកលែងតែក្នុងករណីអភ័យឯកសិទ្ធិទាំងនោះត្រូវបានដកហូតយ៉ាងជាក់ស្តែង។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវយល់ថា គ្មានការដកហូតអភ័យឯកសិទ្ធិណាមួយអាចធ្វើទៅបានចំពោះវិធានការអនុវត្តច្បាប់នោះទេ។

២. ទីស្នាក់ការរបស់អាស៊ានមិនអាចត្រូវបានរំលោភបំពានឡើយ។ ទ្រព្យសម្បត្តិ និងចលនទ្រព្យរបស់អាស៊ាន មិនអាចត្រូវបានឆែកឆេរ រឹបអូស ដកហូត និងរួចផុតពីរាល់ទម្រង់នៃការជ្រៀតជ្រែកផ្សេងៗទៀត ទោះបីតាមរយៈសកម្មភាពនៃអំណាចប្រតិបត្តិ រដ្ឋបាល តុលាការ ឬអំណាចនីតិបញ្ញត្តិ។

៣. រាល់ទម្រង់នៃការប្រាស្រ័យទាក់ទង និងប័ណ្ណសាររបស់អាស៊ាន ព្រមទាំងរាល់ឯកសារទាំងអស់ ទោះនៅទីណាក្តី ឱ្យតែជាកម្មសិទ្ធិរបស់អាស៊ាន ឬគ្រប់គ្រងដោយអាស៊ាន មិនថាជាប្រភេទអេឡិចត្រូនិច ឬជាទម្រង់ផ្សេងៗទៀត ដែលជាព័ត៌មាន ក្នុងនោះអាចត្រូវយកមកប្រើប្រាស់សម្រាប់ជាឯកសារយោងនាពេលអនាគត មិនអាចត្រូវបានរំលោភបំពានឡើយ។

៤. ដោយគ្មានការដាក់កំហិតតាមរយៈការត្រួតពិនិត្យហិរញ្ញវត្ថុ បទបញ្ជា ឬការផ្អាកជាបណ្តោះអាសន្នណាមួយ អាស៊ាន៖
   ក. អាចមានសិទ្ធិមានមូលនិធិ មាស ឬ រូបិយប័ណ្ណណាមួយក៏បាន និងអាចដំណើរការគណនីជារូបិយប័ណ្ណណាមួយក៏បាន។
   ខ. មានសេរីភាពក្នុងការផ្ទេរមូលនិធិ មាស ឬរូបិយប័ណ្ណរបស់ខ្លួន ពីប្រទេសមួយទៅកាន់ប្រទេសមួយទៀតក៏បាន ឬនៅក្នុងប្រទេសណាមួយក៏បាន និងអាចប្តូរពីរូបិយប័ណ្ណមួយដែលខ្លួនកាន់កាប់ ទៅរូបិយប័ណ្ណមួយទៀតបាន។

៥. ទោះបីមានវាក្យខណ្ឌទី៤ នៃមាត្រានេះក៏ដោយ អាស៊ានត្រូវប្រតិបត្តិតាមច្បាប់ និងបទបញ្ជារបស់រដ្ឋសមាជិកពាក់ព័ន្ធទៅនឹងការរាយការណ៍អំពីមូលនិធិ និងចលនាដោះដូររូបិយប័ណ្ណបរទេស។

៦. ក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួន ដែលមានចែងក្នុងវាក្យខណ្ឌទី៤ នៃមាត្រានេះ អាស៊ានត្រូវគោរពចំពោះការប្តឹងតវ៉ាជាផ្លូវការរបស់រដ្ឋាភិបាលនៃរដ្ឋសមាជិក ក្នុងកម្រិតដែលថាការប្តឹងតវ៉ាជាផ្លូវការនោះមិនមានឥទ្ធិពលប៉ះពាល់ដល់ផលប្រយោជន៍អាស៊ាន។

៧. អាស៊ាន និងទ្រព្យសម្បត្តិ និងចលនទ្រព្យរបស់អាស៊ានត្រូវបាន៖
   (ក) រួចផុតពីការបង់ពន្ធផ្ទាល់ទាំងអស់ ប៉ុន្តែត្រូវយល់ថា ទោះជាយ៉ាងណាក្តី អាស៊াননឹងមិនទាមទារការលើកលែងពន្ធតាមភាពជាក់ស្តែង លើសពីកម្រៃសេវាកម្មប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈនោះទេ។
   (ខ) រួចផុតពីកាតព្វកិច្ចពន្ធគយ និងការហាមឃាត់នានា ព្រមទាំងការដាក់កំហិតចំពោះការនាំចូល និងការនាំចេញនូវវត្ថុដែលត្រូវនាំចូល ឬនាំចេញដោយអាស៊ានសម្រាប់ការប្រើប្រាស់ជាផ្លូវការរបស់ខ្លួន។ ប៉ុន្តែ ត្រូវយល់ថា វត្ថុនាំចូលដែលស្ថិតនៅក្រោមល័ក្ខខ័ណ្ឌលើកលែងពន្ធខាងលើ មិនអាចត្រូវបានដាក់លក់នៅក្នុងរដ្ឋសមាជិក ដែលវត្ថុនោះត្រូវបាននាំចូលឡើយ លើកលែងតែស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដែលមានការឯកភាពជាមួយរដ្ឋាភិបាលនៃរដ្ឋសមាជិកនោះ។
   (គ) រួចផុតពីកាតព្វកិច្ចពន្ធគយ និងការហាមឃាត់នានាព្រមទាំងការដាក់កំហិតទាំងឡាយទៅលើការនាំចូល និងការនាំចេញពាក់ព័ន្ធទៅដល់ការផ្សព្វផ្សាយរបស់ខ្លួន។

៨. តាមវិធានទូទៅ ខណៈពេលដែលអាស៊ានមិនអាចប្រកាសសុំការលើកលែងថ្លៃអាករ និងពន្ធដែលខ្លួនត្រូវបង់លើការលក់ចលនទ្រព្យ និងអចលនទ្រព្យ ឬនៅពេលណាដែលអាស៊ានត្រូវបញ្ជាទិញទ្រព្យសម្ភារៈសំខាន់ៗ សម្រាប់

ការប្រើប្រាស់ជាផ្លូវការ ដែលជាប់កាតព្វកិច្ចបង់អាករ និងពន្ធផ្សេងៗនោះ រដ្ឋសមាជិកត្រូវរៀបចំតាមលទ្ធភាពរបស់ខ្លួននូវបែបបទរដ្ឋបាលសមស្រប ដើម្បីបង្វែរ ឬសងមកវិញនូវចំនួនថ្លៃអាករ ឬពន្ធដែលបានបង់រួចហើយនោះ។

៩. ការរួចពន្ធ និងអាករផ្សេងៗ ដែលមានចែងក្នុងមាត្រានេះ មិនអនុវត្តចំពោះពន្ធ និងអាករទាំងឡាយណា ដែលត្រូវបង់ក្រោមច្បាប់របស់រដ្ឋសមាជិកដោយបុគ្គលជាប់កិច្ចសន្យាជាមួយអាស៊ាន។

១០. អាស៊ានត្រូវទទួលបានការជួយសម្រួលនៅក្នុងទឹកដីរបស់រដ្ឋសមាជិកនីមួយៗ ចំពោះការប្រាស្រ័យទាក់ទងជាផ្លូវការរបស់ខ្លួន ឱ្យដូចទៅនឹងការផ្តល់ដោយរដ្ឋាភិបាលរបស់រដ្ឋសមាជិកនោះ ទៅដល់រដ្ឋាភិបាលរបស់រដ្ឋដទៃរួមទាំងបេសកកម្មការទូតក្នុងលក្ខណៈសិទ្ធិអាទិភាព អត្រា និងបន្ទុកពន្ធផ្សេងៗលើលិខិតស្នាម ខ្សែកាប ទូរលេខវិទ្យុទាក់ទង ទូរធាឃាកម្ម ទូរស័ព្ទ និងមធ្យោបាយការប្រាស្រ័យទាក់ទងផ្សេងៗទៀត ព្រមទាំងអត្រាថ្លៃព័ត៌មានសម្រាប់អ្នកសារព័ត៌មាន និងវិទ្យុ។ ចំពោះការឆ្លើយឆ្លងគ្នា និងការប្រាស្រ័យទាក់ទងគ្នាជាផ្លូវការរបស់អាស៊ានមិនអាចត្រូវបានឆ្លងកាត់ការត្រួតពិនិត្យឡើយ។

១១. អាស៊ានមានសិទ្ធិប្រើប្រាស់លេខកូដ ព្រមទាំងសិទ្ធិក្នុងការបញ្ជូន និងការទទួលឯកសារឆ្លងឆ្លើយគ្នា តាមរយៈហារី ឬតាមហិប ដែលត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដូចហារីការទូត និងហិបការទូតផងដែរ។

## មាត្រា ៤
## អគ្គលេខាធិការអាស៊ាន និងបុគ្គលិកនៃលេខាធិការដ្ឋានអាស៊ាន

១. អគ្គលេខាធិការអាស៊ានដែលត្រូវមានការសម្រេចរបស់គណៈកម្មាធិការតំណាងអចិន្ត្រៃយ៍សិន ត្រូវបញ្ជាក់យ៉ាងច្បាស់លាស់អំពីប្រភេទនៃបុគ្គលិករបស់លេខាធិការដ្ឋានអាស៊ាន ដែលបទប្បញ្ញត្តិនៃមាត្រានេះត្រូវអនុវត្តចំពោះបុគ្គលិកទាំងនោះ។ ប្រភេទនៃបុគ្គលិកទាំងនោះត្រូវជូនព័ត៌មានទៅរដ្ឋាភិបាលនៃរដ្ឋសមាជិកទាំងអស់។ ឈ្មោះបុគ្គលិកដែលមាននៅក្នុងប្រភេទទាំងនេះត្រូវជូនព័ត៌មានជាប្រចាំទៅរដ្ឋាភិបាលនៃរដ្ឋសមាជិក។

២. បុគ្គលិកនៃលេខាធិការដ្ឋានអាស៊ាន ដែលត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិក្រោមកិច្ចព្រមព្រៀងនេះ ត្រូវបានផ្តល់អត្តសញ្ញាណប័ណ្ណពិសេស ដែលចេញដោយអគ្គលេខាធិការអាស៊ាន ឬ តំណាងរបស់គាត់ ដែលបញ្ជាក់ថាបុគ្គលិកទាំងនោះជាបុគ្គលិកលេខាធិការដ្ឋានអាស៊ាន។

៣. ក្នុងពេលបំពេញការងារ និងអនុវត្តដោយឯករាជ្យ នូវកណើយកិច្ច មុខនាទី និងការទទួលខុសត្រូវរបស់ខ្លួន អគ្គលេខាធិការអាស៊ាន និងបុគ្គលិករបស់លេខាធិការដ្ឋានអាស៊ាន យោងតាមវាក្យខណ្ឌទី១ នៃមាត្រានេះ ត្រូវ៖

(ក) មានអភ័យឯកសិទ្ធិរួចផុតពីដំណើរការតាមផ្លូវតុលាការចំពោះការប្រើពាក្យពេចន៍ថ្លែងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ និងរាល់សកម្មភាពដែលបានប្រព្រឹត្តក្នុងសមត្ថកិច្ចផ្លូវការរបស់ខ្លួន។

(ខ) ទទួលបានការលើកលែងពន្ធលើប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ ដែលចំណាយដោយអាស៊ាន។

(គ) រួចផុតពីកាតព្វកិច្ចបម្រើជាតិ។ល។

(ឃ) រួមជាមួយទាំងសហព័ទ្ធ កូនក្នុងបន្ទុក និងកូនជាអនីតិជន មានអភ័យឯកសិទ្ធិរួចផុតពីការដាក់កំហិតអន្តោប្រវេសន៍ និងការចុះបញ្ជីជនបរទេស។

(ង) ទទួលបាននូវបុព្វសិទ្ធិទាក់ទងទៅនឹងការសម្របសម្រួលក្នុងការដោះដូរ ដូចគ្នាទៅនឹងបុព្វសិទ្ធិដែលផ្តល់ចំពោះមន្ត្រីឋានៈប្រហាក់ប្រហែលគ្នា នៅក្នុងបេសកកម្មការទូត។

(ច) រួមជាមួយទាំងសហព័ទ្ធ សាច់ញាតិ និងកូនៗ ទទួលនូវការជួយសម្រួលមធ្យោបាយធ្វើមាតុភូមិនិវត្តន៍នៅពេលមានវិបត្តិអន្តរជាតិ ក្នុងឋានៈជាបេសកជនការទូត។

(ឆ) មានសិទ្ធិនាំចូលដោយរួចពន្ធនូវគ្រឿងសង្ហារឹម និងវត្ថុផ្សេងៗទៀត ក្នុងនោះរួមមាន រថយន្តមួយគ្រឿងនៅពេលចាប់ផ្តើមបំពេញការងារដំបូង នៅក្នុងរដ្ឋសមាជិកដែលលេខាធិការដ្ឋានអាស៊ានតាំងនៅ។

៤. បន្ថែមលើបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលបានបញ្ជាក់ក្នុងវាក្យខណ្ឌទី៣ នៃមាត្រានេះ អគ្គលេខាធិការអាស៊ាន និងអគ្គលេខាធិការរងអាស៊ានទាំងអស់ រាប់ទាំងសហព័ទ្ធ និងកូនជាអនីតិជនត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិអញ្ញត្រកម្ម និងកិច្ចសម្រួលផ្សេងៗ ដូចដែលបានផ្តល់ជូនបេសកជនការទូត ដោយអនុលោមតាមច្បាប់អន្តរជាតិ។

៥. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃមាត្រានេះ លើកលែងតែវាក្យខណ្ឌទី៣(ក) មិនត្រូវអនុវត្តចំពោះបុគ្គល ដូចមានចែងក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ ដែលជាជនជាតិនៃរដ្ឋសមាជិកផ្តល់សិទ្ធិ ឬមាននិវេសនដ្ឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋសមាជិកដែលជាអ្នកផ្តល់សិទ្ធិនេះ។

៦. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ត្រូវផ្តល់ជូនអគ្គលេខាធិការអាស៊ាន និងបុគ្គលិករបស់លេខាធិការដ្ឋានអាស៊ាន ដែលមានចែងនៅក្នុងវាក្យខណ្ឌទី១នៃមាត្រានេះ សម្រាប់បម្រើផលប្រយោជន៍អាស៊ាន និងមិនមែនសម្រាប់ផលប្រយោជន៍បុគ្គលឡើយ។ អគ្គលេខាធិការអាស៊ានមានសិទ្ធិ និងករណីយកិច្ចដកហូតអភ័យឯកសិទ្ធិរបស់សមាជិកណាមួយ ដែលជាបុគ្គលិករបស់លេខាធិការដ្ឋានអាស៊ាន ក្នុងករណីយល់ឃើញថា អភ័យឯកសិទ្ធិដែលបានផ្តល់ជូននោះអាចប៉ះពាល់ដល់វិស័យយុត្តិធម៌ ហើយការដកអភ័យឯកសិទ្ធិនេះ មិនបង្កឱ្យមានព្យសនកម្មដល់ផលប្រយោជន៍អាស៊ាន។ អភ័យឯកសិទ្ធិរបស់អគ្គលេខាធិការអាស៊ានអាចត្រូវដកហូតដោយកិច្ចប្រជុំកំពូលអាស៊ាន ឬដោយនរណាម្នាក់ ដែលកិច្ចប្រជុំកំពូលអាស៊ានផ្តល់សិទ្ធិជូន។

៧. អគ្គលេខាធិការអាស៊ានត្រូវសហការគ្រប់ពេលវេលាជាមួយអាជ្ញាធរនៃរដ្ឋសមាជិកអាស៊ាន ដើម្បីជួយសម្រួលដល់រដ្ឋបាលយុត្តិធម៌ ធានាឱ្យមានការគោរពបទបញ្ជារបស់នគរបាល និងទប់ស្កាត់ការរំលោភបំពានលើបុព្វសិទ្ធិ អភ័យឯកសិទ្ធិ និងកិច្ចសម្របសម្រួលដទៃទៀត នៅក្រោមមាត្រានេះ។

## មាត្រា ៥
## អ្នកជំនាញការបំពេញបេសកកម្មសម្រាប់អាស៊ាន

១. នៅពេលយល់ឃើញថាសមស្រប រដ្ឋសមាជិកនីមួយៗត្រូវផ្តល់ជូនទៅឱ្យអ្នកជំនាញការបំពេញបេសកកម្មសម្រាប់អាស៊ាននូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិខ្លះ ឬទាំងអស់ ដោយគ្មានការកម្រិត ដូចខាងក្រោម ៖

(ក) អភ័យឯកសិទ្ធិរួចពីការឃុំឃាំង ឬការចាប់ខ្លួន និងការរឹបអូសហិបឥវ៉ាន់ផ្ទាល់ខ្លួន។

(ខ) អភ័យឯកសិទ្ធិលើដំណើរការតាមផ្លូវតុលាការ ចំពោះពាក្យពេចន៍ថ្លែងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ និងរាល់កិច្ចទាំងឡាយ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលបំពេញបេសកកម្ម។ អភ័យឯកសិទ្ធិនេះត្រូវបន្ត ទោះបីជាបុគ្គលពាក់ព័ន្ធនោះមិនស្ថិតនៅក្នុងពេលកំពុងបំពេញបេសកកម្មសម្រាប់អាស៊ាន ឬចូលរួមសកម្មភាពផ្លូវការអាស៊ាន ក្នុងនាមរដ្ឋសមាជិកក៏ដោយ។

(គ) ភាពមិនអាចប៉ះពាល់បានលើរាល់ឯកសារ និងលិខិតស្នាមទាំងអស់។

(ឃ) សិទ្ធិក្នុងការប្រើប្រាស់លេខសម្ងាត់ និងទទួលលិខិតស្នាម ឬលិខិតឆ្លើយឆ្លង តាមរយៈហាវី ឬតាមហិបបិទជិតមានបោះត្រា ក្នុងគោលបំណងនៃការប្រាស្រ័យទាក់ទងជាមួយអាស៊ាន។

(ង) ការទទួលបានកិច្ចសម្របសម្រួលចំពោះការកម្រិត និងការដោះដូររូបិយប័ណ្ណ ដូចបានផ្តល់ជូនតំណាងរដ្ឋាភិបាលបរទេស ក្នុងពេលបំពេញបេសកកម្មផ្លូវការជាបណ្តោះអាសន្ន។

(ច) អភ័យឯកសិទ្ធិ និងកិច្ចសម្របសម្រួល ចំពោះហិបឥវ៉ាន់ផ្ទាល់ខ្លួន ដូចបានផ្តល់ជូនបេសកជនការទូត។

២. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ត្រូវបានផ្តល់ជូនអ្នកជំនាញការនានា ក្នុងផលប្រយោជន៍អាស៊ាន និងមិនមែនសម្រាប់ផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួននោះទេ។ អគ្គលេខាធិការអាស៊ានមានសិទ្ធិ និងករណីយកិច្ចដកហូតអភ័យឯកសិទ្ធិពីជំនាញការណាមួយ ក្នុងករណីយល់ឃើញថា អភ័យឯកសិទ្ធដែលបានផ្តល់ជូននេះអាចប៉ះពាល់ដល់វិស័យយុត្តិធម៌ ហើយការដកហូតអភ័យឯកសិទ្ធិនេះ មិនបង្កឱ្យមានព្យសនកម្មដល់ផលប្រយោជន៍អាស៊ាន។

៣. នៅមុនពេលអ្នកជំនាញការចាប់ផ្តើមបំពេញបេសកកម្មសម្រាប់អាស៊ាន អគ្គលេខាធិការអាស៊ានត្រូវ៖

(ក) ជូនដំណឹងទៅលេខាធិការដ្ឋានជាតិអាស៊ាននៃរដ្ឋសមាជិកអាស៊ាន ដែលអ្នកជំនាញការនោះត្រូវទៅបំពេញបេសកកម្ម អំពីឈ្មោះ ប្រភេទបេសកកម្ម និងរយៈពេលនៃការស្នាក់នៅរបស់អ្នកជំនាញការ ដែលត្រូវបានចាត់ឱ្យបំពេញបេសកកម្មសម្រាប់អាស៊ាន។ និង

(ខ) ចេញឯកសារអត្តសញ្ញាណកម្មជូនអ្នកជំនាញការនោះ ដែលត្រូវចាត់ឱ្យបំពេញបេសកកម្មសម្រាប់អាស៊ានក្នុងករណីចាំបាច់។

## មាត្រា ៦
## បេសកកម្មអចិន្ត្រៃយ៍

រាល់បទបញ្ញត្តិពាក់ព័ន្ធទាំងឡាយស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលទាក់ទងនឹងបេសកកម្មការទូត ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងវីយែន ត្រូវយកមកអនុវត្តចំពោះបេសកកម្មអចិន្ត្រៃយ៍។

## មាត្រា ៧
## តំណាងអចិន្ត្រៃយ៍ និងមន្ត្រីកំពុងបំពេញភារកិច្ចអាស៊ាន

១. រាល់បទបញ្ញត្តិពាក់ព័ន្ធនៅក្នុងអនុសញ្ញាទីក្រុងវីយែនទាក់ទងទៅនឹងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ សម្រាប់ភ្នាក់ងារការទូត ព្រមទាំងសមាជិកក្រុមគ្រួសារ ដែលជាផ្នែកនៃរង្វង់គ្រួសាររបស់ភ្នាក់ងារការទូត ត្រូវយកមកអនុវត្តចំពោះតំណាងអចិន្ត្រៃយ៍ និងមន្ត្រីកំពុងបំពេញភារកិច្ចអាស៊ាន ព្រមទាំងសមាជិកក្រុមគ្រួសាររបស់តំណាងអចិន្ត្រៃយ៍ និងមន្ត្រីកំពុងបំពេញភារកិច្ចអាស៊ាននោះ ខណៈពេលកំពុងស្ថិតនៅក្នុងរដ្ឋសមាជិក ដែលលេខាធិការដ្ឋានអាស៊ានតាំងនៅ។

២. រាល់បទបញ្ញត្តិស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ដែលពាក់ព័ន្ធទៅនឹងមន្ត្រីរបស់រដ្ឋសមាជិក ក្រោមមាត្រា៩នៃកិច្ចព្រមព្រៀងនេះ ត្រូវយកមកអនុវត្តចំពោះតំណាងអចិន្ត្រៃយ៍ បើមានការចាំបាច់ និងមន្ត្រីកំពុងបំពេញភារកិច្ចអាស៊ាននៅក្នុងពេលចូលរួមសកម្មភាពផ្លូវការរបស់អាស៊ាន ឬតំណាងឱ្យអាស៊ាននៅក្នុងរដ្ឋសមាជិកក្រៅពីរដ្ឋសមាជិកដែលលេខាធិការដ្ឋានអាស៊ានតាំងនៅ។

៣. បុព្វសិទ្ធ និងអភ័យឯកសិទ្ធិ ត្រូវបានផ្តល់ជូនតំណាងអចិន្ត្រៃយ៍ និងមន្ត្រីកំពុងបំពេញភារកិច្ចអាស៊ាន ដើម្បីការពារការអនុវត្តន៍មុខងារពាក់ព័ន្ធនឹងអាស៊ានដោយឯករាជ្យ និងមិនមែនប្រើប្រាស់សម្រាប់ផលប្រយោជន៍បុគ្គលផ្ទាល់ខ្លួន។ ហេតុដូច្នេះ រដ្ឋសមាជិកមួយមិនត្រឹមតែមានសិទ្ធិប៉ុណ្ណោះទេ ប៉ុន្តែមានករណីយកិច្ចដកហូតអភ័យឯកសិទ្ធិរបស់តំណាងអចិន្ត្រៃយ៍ និងមន្ត្រីកំពុងបំពេញភារកិច្ចអាស៊ាន ក្នុងករណីរដ្ឋសមាជិកនោះយល់ថា អភ័យឯកសិទ្ធិដែលបានផ្តល់ជូន អាចប៉ះពាល់ដល់វិស័យយុត្តិធម៌ ហើយការដកអភ័យឯកសិទ្ធិនេះមិនបង្កឱ្យមានព្យសនកម្មដល់គោលបំណងរបស់អភ័យឯកសិទ្ធិ ដែលបានផ្តល់ជូន។

## មាត្រា ៨
## បុគ្គលិកស្ថានបេសកកម្មអចិន្ត្រៃយ៍

១. រាល់បទបញ្ញត្តិពាក់ព័ន្ធទាំងឡាយណានៅក្នុងអនុសញ្ញាទីក្រុងវីយែន ដែលទាក់ទងដល់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសម្រាប់សមាជិកនៃក្រុមបុគ្គលិករដ្ឋបាល និងបច្ចេកទេសនៃស្ថានបេសកកម្មការទូត និងសមាជិកក្រុមគ្រួសាររបស់សមាជិកទាំងនោះ ត្រូវយកមកអនុវត្តចំពោះសមាជិកនៃក្រុមបុគ្គលិករដ្ឋបាល និងបច្ចេកទេសនៃស្ថានបេសកកម្មអចិន្ត្រៃយ៍ និងក្រុមគ្រួសាររបស់គេ។

២. រាល់បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយណា នៅក្នុងអនុសញ្ញាទីក្រុងវីយែន ដែលទាក់ទងដល់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិសម្រាប់សមាជិកនៃក្រុមបុគ្គលិកផ្នែកសេវាកម្មនៃស្ថានបេសកកម្មការទូត ត្រូវយកមកអនុវត្តចំពោះសមាជិកនៃក្រុមបុគ្គលិកផ្នែកសេវាកម្មនៃស្ថានបេសកកម្មអចិន្ត្រៃយ៍។

៣. ប្រសិនអ្នកបម្រើការឯកជនដែលមិនមែនជាជនជាតិនៃរដ្ឋសមាជិក ឬពុំមាននិវេសនដ្ឋានអចិន្ត្រៃយ៍ នៅក្នុងរដ្ឋសមាជិក ដែលលេខាធិការដ្ឋានអាស៊ានតាំងនៅ អ្នកបម្រើការឯកជនទាំងនោះត្រូវទទួលបានការលើកលែងពន្ធ និងអាករលើប្រាក់កម្រៃ ដែលបានទទួលពីការបំពេញការងារ។ អ្នកបម្រើការឯកជននេះអាចមានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិផ្សេងទៀតបានតាមរដ្ឋសមាជិកដែលលេខាធិការដ្ឋានតាំងនៅផ្តល់ជូនតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋសមាជិកដែលលេខាធិការដ្ឋានអាស៊ានតាំងនៅ ត្រូវអនុវត្តយុត្តាធិការលើបុគ្គលទាំងនោះ ក្នុងបែបបទបែបនេះ ដែលមិនជ្រៀតជ្រែកដោយហួសហេតុដល់ការបំពេញមុខងារនៃស្ថានបេសកកម្មអចិន្ត្រៃយ៍។

៤. សមាជិកផ្សេងទៀតនៃក្រុមបុគ្គលិករបស់ស្ថានបេសកកម្មអចិន្ត្រៃយ៍ និងអ្នកបម្រើការឯកជនដែលជាជនជាតិនៃរដ្ឋសមាជិក ឬមាននិវេសនដ្ឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋសមាជិកដែលលេខាធិការដ្ឋានអាស៊ានតាំងនៅ ត្រូវទទួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិមួយចំនួនតាមរដ្ឋសមាជិកដែលលេខាធិការដ្ឋានអាស៊ានតាំងនៅផ្តល់ឱ្យតែប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋសមាជិកដែលមានលេខាធិការដ្ឋានអាស៊ានតាំងនៅ ត្រូវអនុវត្តយុត្តាធិការលើបុគ្គលទាំងនោះ ក្នុងបែបបទបែបនេះ ដែលមិនជ្រៀតជ្រែកដោយហួសហេតុដល់ការបំពេញមុខងារនៃស្ថានបេសកកម្មអចិន្ត្រៃយ៍។

## មាត្រា ៩
## មន្ត្រីនៃរដ្ឋសមាជិក

១. ក្នុងពេលចូលរួមក្នុងសកម្មភាពផ្លូវការរបស់អាស៊ាន ឬតំណាងឱ្យអាស៊ាននៅក្នុងរដ្ឋសមាជិក មន្ត្រីនៃរដ្ឋសមាជិកត្រូវទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដូចខាងក្រោម ក្នុងករណីចាំបាច់ ដើម្បីអនុវត្តមុខងាររបស់ខ្លួន៖

(ក) អភ័យឯកសិទ្ធិរួចពីការឃុំខ្លួន ឬការចាប់ខ្លួន និងការរឹបអូសហិបឥវ៉ាន់ផ្ទាល់ខ្លួន និងអភ័យឯកសិទ្ធិចំពោះពាក្យពេចន៍ថ្លែងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ និងរាល់សកម្មភាពដែលបានប្រព្រឹត្ត ក្នុងឋានៈជាតំណាង និងអភ័យឯកសិទ្ធិរួចផុតពីដំណើរការតាមផ្លូវតុលាការតាមគ្រប់រូបភាព។

(ខ) ភាពមិនអាចប៉ះពាល់បានលើរាល់លិខិតស្នាម និងឯកសារទាំងអស់។

(គ) សិទ្ធិក្នុងការប្រើប្រាស់លេខសម្ងាត់ និងការទទួលលិខិតស្នាម ឬការឆ្លើយឆ្លងតាមរយៈហាវី ឬតាមហិបបិទបោះត្រា។

(ឃ) ការសម្រួលក្នុងការដាក់កម្រិតចំពោះការដោះដូររូបិយប័ណ្ណ ដូចដែលបានផ្តល់ជូនតំណាងរដ្ឋាភិបាលបរទេសក្នុងពេលបំពេញបេសកកម្មផ្លូវការជាបណ្តោះអាសន្ន។

(ង) អភ័យឯកសិទ្ធិ និងការសម្រួលចំពោះហិបឥវ៉ាន់ផ្ទាល់ខ្លួន ដូចដែលបានផ្តល់ជូនបេសកជនការទូត។

២. ដើម្បីធានាដល់មន្ត្រីនៃរដ្ឋសមាជិក ចំពោះសេរីភាពពេញលេញក្នុងការបញ្ចេញមតិ និងឯករាជ្យភាព ក្នុងការបំពេញការងាររបស់ខ្លួន អភ័យឯកសិទ្ធិរួចពីដំណើរការតាមផ្លូវតុលាការចំពោះពាក្យពេចន៍ថ្លែងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ និងរាល់សកម្មភាពដែលបានប្រព្រឹត្ត ក្នុងការក្នុងការបំពេញភារកិច្ចទាំងនេះ នឹងត្រូវផ្តល់បន្តជូនរហូត ទោះបីបុគ្គលពាក់ព័ន្ធទាំងនោះលែងជាមន្ត្រីនៃរដ្ឋសមាជិកក៏ដោយ។

៣. បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ត្រូវបានផ្តល់ជូនមន្ត្រីនៃរដ្ឋសមាជិក ដើម្បីការពារការអនុវត្តន៍ដោយឯករាជ្យនូវមុខងារទាក់ទងនឹងអាស៊ាន និងមិនមែនសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗនោះទេ។ ហេតុដូច្នេះហើយ រដ្ឋសមាជិកមិនត្រឹមតែមានសិទ្ធិនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានករណីយកិច្ចអាចដកហូតអភ័យឯកសិទ្ធិពីមន្ត្រីនៃរដ្ឋសមាជិកអាស៊ានណាមួយបាន ក្នុងករណីយល់ថា អភ័យឯកសិទ្ធិដែលបានផ្តល់ជូនអាចប៉ះពាល់ដល់ដំណើរការយុត្តិធម៌ ហើយការដកអភ័យឯកសិទ្ធិនេះ មិនប៉ះពាល់ដល់គោលបំណងរបស់អភ័យឯកសិទ្ធិដែលបានផ្តល់ជូន។

៤. បទប្បញ្ញត្តិនៃវាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២នៃមាត្រានេះ មិនអាចអនុវត្តបានឡើយចំពោះទំនាក់ទំនងរវាងមន្ត្រីនៃរដ្ឋសមាជិក ជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសមាជិក ជាទីដែលមន្ត្រីរូបនោះជាពលរដ្ឋ ឬជានិវេសនជនអចិន្ត្រៃយ៍ ឬជាទីដែលមន្ត្រីរូបនោះធ្លាប់បម្រើការងារ។

## មាត្រា ១០
## កិច្ចសហប្រតិបត្តិការ និងការប្រតិបត្តិ

១. ក្នុងនាមជាអង្គការអន្តររដ្ឋាភិបាល បើសិនជាមានលទ្ធភាព អាស៊ានត្រូវធ្វើសហការគ្រប់ពេលវេលា ជាមួយអាជ្ញាធរពាក់ព័ន្ធរបស់រដ្ឋសមាជិក ដើម្បីជួយសម្រួលរដ្ឋបាលយុត្តិធម៌ឱ្យមានសុក្រឹតភាព ធានាការគោរពច្បាប់ និងបទបញ្ជានានា និងទប់ស្កាត់ការកើតឡើងនៃការរំលោភលើបុគ្គលដែលទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ក្រោមកិច្ចព្រមព្រៀងនេះ។

២. រដ្ឋសមាជិកត្រូវធានាថា បុគ្គលគ្រប់រូបដែលទទួលបានការតែងតាំង ឬបំពេញមុខងារ ដែលទទួលបានបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិក្រោមកិច្ចព្រមព្រៀងនេះ ត្រូវគោរពច្បាប់ និងបទបញ្ញត្តិនានារបស់រដ្ឋសមាជិកដែលខ្លួនកំពុងស្ថិតនៅ ក្នុងលក្ខណៈស្របទៅតាមបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលបុគ្គលទាំងនោះទទួលបាន។

## មាត្រា ១១
## ការដោះស្រាយជម្លោះ

ជម្លោះទាំងឡាយដែលកើតចេញពីការបកស្រាយ ឬការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយប្រកបដោយមិត្តភាព អនុលោមតាមជំពូកទី ៨ នៃធម្មនុញ្ញអាស៊ាន។

## មាត្រា ១២
## ការធ្វើវិសោធនកម្ម

១. ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះអាចធ្វើឡើងបាន នៅពេលណាក៏បានដោយកុងសង់ស៊ីសក្នុងចំណោមរដ្ឋសមាជិកទាំងអស់ និងត្រូវផ្តល់សច្ចាប័នដោយរដ្ឋសមាជិកទាំងអស់ ដោយអនុលោមតាមនីតិវិធីផ្ទៃក្នុងរបស់រដ្ឋសមាជិករៀងៗខ្លួន។

២. ការធ្វើវិសោធនកម្មត្រូវចូលជាធរមាន ៣០ថ្ងៃ បន្ទាប់ពីអគ្គលេខាធិការអាស៊ានបានទទួលលិខិតុបករណ៍ចុងក្រោយស្តីពីការផ្តល់សច្ចាប័ន។

## មាត្រា ១៣
## អវសានប្បញ្ញត្តិ

១. កិច្ចព្រមព្រៀងនេះត្រូវចុះហត្ថលេខាដោយរដ្ឋសមាជិកទាំងអស់។

២. កិច្ចព្រមព្រៀងនេះត្រូវផ្តល់សច្ចាប័នដោយរដ្ឋសមាជិកទាំងអស់ ដោយអនុលោមតាមនីតិវិធីផ្ទៃក្នុងរបស់រដ្ឋសមាជិករៀងៗខ្លួន។

៣. លិខិតុបករណ៍នៃការផ្តល់សច្ចាប័នត្រូវតម្កល់ទុកជាមួយអគ្គលេខាធិការអាស៊ាន ដែលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋសមាជិកទាំងអស់ ស្តីពីការតម្កល់ទុកលិខិតុបករណ៍នីមួយៗ។

៤. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន ៣០ថ្ងៃ បន្ទាប់ពីអគ្គលេខាធិការអាស៊ានបានទទួលលិខិតុបករណ៍ទីដប់នៃការផ្តល់សច្ចាប័ន។

ជាសក្ខីកម្មនៅទីនេះ ហត្ថលេខីដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ត្រូវបានអនុញ្ញាតយ៉ាងពិតប្រាកដដោយប្រមុខរដ្ឋ/រដ្ឋាភិបាលនៃប្រទេសសមាជិកនីមួយៗ។

ធ្វើនៅនាអាម-ហួហ៊ីន ប្រទេសថៃឡង់ដ៍ ថ្ងៃទីម្ភៃប្រាំ ខែតុលា ឆ្នាំពីរពាន់ប្រាំបួន តែមួយច្បាប់គត់ជាភាសាអង់គ្លេស

តំណាងប្រ៊ុយណេដារូស្សាឡាម

**លឹម ជុក សេង**
**រដ្ឋមន្ត្រីទី២ កិច្ចការបរទេស និងពាណិជ្ជកម្ម**

តំណាងព្រះរាជាណាចក្រកម្ពុជា

**ហោ ណាំហុង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

តំណាងសាធារណរដ្ឋឥណ្ឌូនេស៊ី

**បណ្ឌិត រ.ម. ម៉ាទី ម.ណាតាលីហ្គាវ៉ា**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

**បណ្ឌិត ថុងលុន ស៊ីសូលីត**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស**

តំណាងម៉ាឡេស៊ី

**ដាតុ អានីហ្វា អាម៉ែន**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសហភាពមីយ៉ាន់ម៉ារ

**វៀន ធីន**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសាធារណរដ្ឋហ្វីលីពីន

**អាល់បឺរតូ រ៉ូម៉ូឡូ**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសាធារណរដ្ឋសិង្ហបុរី

**ដុច យ៉ុង-ម៉ុន យូច**
**រដ្ឋមន្ត្រីការបរទេស**

តំណាងព្រះរាជាណាចក្រថៃឡង់ដ៍

**ភាស៊ីត គីរម្យ៉ា**
**រដ្ឋមន្ត្រីការបរទេស**

តំណាងសាធារណរដ្ឋសង្គមនិយមវៀតណាម

**បណ្ឌិត ផាម យ៉ា មៀម**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស**

**AGREEMENT ON THE PRIVILEGES AND IMMUNITIES OF THE ASSOCIATION OF SOUTHEAST ASIAN NATIONS**

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (ASEAN), hereinafter collectively referred to as "Member States" or individually as "Member State";

**RECALLING** the ASEAN Charter signed in Singapore on 20 November 2007;

**RECOGNISING** that Article 3 of the ASEAN Charter confers on ASEAN, as an inter-governmental organisation, legal personality; and

**FURTHER RECOGNISING** that Articles 17, 18 and 19 of the ASEAN Charter accord privileges and immunities to ASEAN in the territories of its Member States as are necessary for the fulfilment of its purposes; the Secretary-General of ASEAN and staff of the ASEAN Secretariat as are necessary for the independent exercise of their functions; and the Permanent Representatives of the Member States to ASEAN, officials of the Member States and officials on ASEAN duties as are necessary for the exercise of their functions, respectively,

HAVE AGREED AS FOLLOWS:

**Article 1**
**Definitions**

In this Agreement, the terms:

1. "Host Member State" means the Member State where the ASEAN Secretariat or other ASEAN institution or institutions are situated;

2. "Members of the administrative and technical staff" means members of the staff of the Permanent Mission employed in the administrative and technical service of the Permanent Mission";

3. "Members of the service staff" means members of the staff of the Permanent Mission employed in the domestic service of the Permanent Mission;

4. "Official ASEAN activities" means meetings, conferences and activities of the organs of ASEAN referred to in Chapter IV of the ASEAN Charter in the exercise of their tasks and functions;

5. "Officials of the Member States" means persons duly appointed by a Member State to act in an official capacity and who participate in official ASEAN activities in that capacity on behalf of that Member State, or who are appointed by an appropriate organ of ASEAN referred to in Chapter IV of the ASEAN Charter as its representatives in the Member States, who are:

(a) in possession of a diplomatic or official passport; or

(b) notified to the receiving Member State, either through diplomatic channels or to the agency



CERTIFIED COPY DEPUTY SECRETARY-GENERAL THE asean

prescribed by the receiving Member State, as persons to be accorded the privileges and immunities under this Agreement, which privileges and immunities may be denied by the receiving Member State, in accordance with the provisions of the ASEAN Charter and relevant principles of international law.

6. "Officials on ASEAN duties" means persons appointed by each Member State to be members of the Permanent Mission, having diplomatic rank, with the duty of supporting the functions of the Permanent Representative;

7. "Permanent Mission" means the mission of a Member State to ASEAN based in Jakarta, headed by the Permanent Representative of that Member State;

8. "Permanent Representative" means the person appointed as Permanent Representative to ASEAN, with the rank of Ambassador, by each Member State to be based in Jakarta, with the duty of acting in that capacity;

9. "Premises of ASEAN" means the buildings or parts of buildings and the land ancillary thereto, irrespective of ownership, used for the purposes of ASEAN, including the residence of the Secretary-General of ASEAN;

10. "Premises of the Permanent Mission" means the buildings or parts of buildings and the land ancillary thereto, irrespective of ownership, used for the purposes of the Permanent Mission, including the residence of the Permanent Representative;

11. "Private servants" means persons who are in the domestic service of any member of the Permanent Mission and who are not employees of the sending Member State;

12. "Property and assets of ASEAN" means all property, whether immovable or movable, which belong to ASEAN, wherever located and by whomsoever held;

13. "Vienna Convention" means the 1961 Vienna Convention on Diplomatic Relations.

## Article 2
## Legal Personality

1. As a legal person, ASEAN shall have the following capacities under domestic laws:

(a) to enter into contracts;

(b) to acquire and dispose of movable and immovable property; and

(c) to institute and defend itself in legal proceedings.

In the exercise of these capacities, ASEAN shall be represented by the Secretary-General of ASEAN, Deputy Secretaries-General or any member of the staff of the ASEAN Secretariat authorised by the Secretary-General of ASEAN.

2. In exercising its capacities under international law, including the power to conclude agreements under Article 41 (7) of the ASEAN Charter, ASEAN shall act through its representatives authorised by the Member States.

## Article 3
## ASEAN

1. ASEAN and the property and assets of ASEAN shall enjoy immunity from every form of legal process except insofar as in

any particular case it has expressly waived its immunity. It is, however, understood that no waiver of immunity shall extend to any measure of execution.

2. The premises of ASEAN shall be inviolable. The property and assets of ASEAN shall be immune from search, requisition, confiscation, expropriation and any other form of interference, whether by executive, administrative, judicial or legislative action.

3. All forms of communications and the archives of ASEAN, and in general all documents wherever located, belonging to it or held by it, whether in electronic or any other form where the information contained therein can be retrieved for future reference, shall be inviolable.

4. Without being restricted by financial controls, regulations or moratoria of any kind, ASEAN:

(a) may hold funds, gold or currency of any kind and operate accounts in any currency; and

(b) shall be free to transfer its funds, gold or currency from one country to another or within any country and to convert any currency held by it into any other currency.

5. Notwithstanding Paragraph 4 of this Article, ASEAN shall comply with the laws and regulations of the Member States relating to the reporting of funds and foreign exchange movements.

6. In exercising its rights in Paragraph 4 of this Article, ASEAN shall pay due regard to any representations made by the Government of any Member State insofar as it is



8/22

considered that effect can be given to such representations without detriment to the interests of ASEAN.

7. ASEAN and the property and assets of ASEAN shall be:

(a) exempt from all direct taxes; it is understood, however, that ASEAN will not claim exemption from taxes which are, in fact, no more than charges for public utility services;

(b) exempt from customs duties and prohibitions and restrictions on imports and exports in respect of articles imported or exported by ASEAN for its official use. It is understood, however, that articles imported under such exemption will not be sold in the Member State into which they were imported except under conditions agreed with the Government of that Member State;

(c) exempt from customs duties and prohibitions and restrictions on imports and exports in respect of its publications.

8. While ASEAN will not, as a general rule, claim exemption from excise duties and from taxes on the sale of movable and immovable property which form part of the price to be paid, nevertheless when ASEAN is making important purchases for official use of property on which such duties and taxes have been charged or are chargeable, Member States will, whenever possible, make appropriate administrative arrangements for the remission or return of the amount of duty or tax.

9. The exemption from taxation and duties referred to in this Article shall not apply to such taxes and dues payable under the law of the Member States by persons contracting with ASEAN.





CERTIFIED CO... DEPUTY SECRETARY... asean

10. ASEAN shall enjoy in the territory of each Member State for its official communications treatment not less favourable than that accorded by the Government of that Member State to any other Government including its diplomatic mission in the matter of priorities, rates and taxes on mails, cables, telegrams, radiograms, telephotos, telephones and other communications; and press rates for information to the press and radio. No censorship shall be applied to the official correspondence and other official communications of ASEAN.

11. ASEAN shall have the right to use codes and to dispatch and receive its correspondence by courier or in bags, which shall have the same privileges and immunities as diplomatic couriers and bags.

## Article 4
## Secretary-General of ASEAN and Staff of the ASEAN Secretariat

1. The Secretary-General of ASEAN, subject to the decision of the Committee of Permanent Representatives, shall specify the categories of staff of the ASEAN Secretariat to which the provisions of this Article apply. These categories shall be communicated to the Governments of all Member States. The names of the persons included in these categories shall from time to time be made known to the Governments of Member States.

2. The staff of the ASEAN Secretariat who are entitled to privileges and immunities under this Agreement shall be provided with special Identification Cards issued by the Secretary-General of ASEAN or his or her authorised representative that identify them as such persons.



CERTIFIED CO... DEPUTY SECRETARY-GENERAL, THE ... asean

3. The Secretary-General of ASEAN and the staff of the ASEAN Secretariat referred to in Paragraph 1 of this Article shall, while in the performance of and for the independent exercise of their respective duties, functions and responsibilities:

(a) be immune from legal process in respect of words spoken or written and all acts performed by them in their official capacity;

(b) be exempt from taxation on the salaries and emoluments paid to them by ASEAN;

(c) be immune from national service obligations;

(d) be immune, together with their spouses, dependent children, and minor children, from immigration restrictions and alien registration;

(e) be accorded the same privileges in respect of exchange facilities as are accorded to the officials of comparable ranks forming part of diplomatic missions to the Government concerned;

(f) be given, together with their spouses, relatives and children, the same repatriation facilities in time of international crisis as diplomatic envoys;

(g) have the right to import free of duty their furniture and effects, including one motor vehicle, at the time of first taking up their post in the host Member State.

4. In addition to the privileges and immunities specified in Paragraph 3 of this Article, the Secretary-General of ASEAN and all Deputy Secretaries-General of ASEAN shall be accorded in respect of themselves, their spouses and minor



CERTIFIED COPY
DEPUTY SECRETARY
asean

children, the privileges and immunities, exemptions and facilities accorded to diplomatic envoys, in accordance with international law.

5. The privileges and immunities under this Article, except Paragraph 3(a), shall not apply to persons referred to in Paragraph 1 of this Article, who are nationals of or permanently resident in the granting Member State.

6. Privileges and immunities are granted to the Secretary-General of ASEAN and staff of the ASEAN Secretariat referred to in Paragraph 1 of this Article in the interests of ASEAN and not for the personal benefit of the individuals themselves. The Secretary-General of ASEAN shall have the right and the duty to waive the immunity of any member of the staff of the ASEAN Secretariat in any case where, in his or her opinion, the immunity would impede the course of justice and can be waived without prejudice to the interests of ASEAN. The immunity of the Secretary-General of ASEAN may be waived by the ASEAN Summit, or by whomsoever authorised by the ASEAN Summit.

7. The Secretary-General of ASEAN shall cooperate at all times with the appropriate authorities of Member States to facilitate the proper administration of justice, secure the observance of police regulations and prevent the occurrence of any abuse in connection with the privileges, immunities and facilities provided under this Article.

## Article 5
## Experts on Missions for ASEAN

1. Each Member State shall, where it considers appropriate, accord any or all of, but not limited to, the following privileges and immunities to experts on missions for ASEAN:



CERTIFIED COPY DEPUTY SECRETARY GENERAL THE ASEAN asean

(a) immunity from personal arrest or detention and from seizure of their personal baggage;

(b) in respect of words spoken or written and acts done by them in the course of the performance of their mission, immunity from legal process of every kind. This immunity from legal process shall continue to be accorded notwithstanding that the persons concerned are no longer employed on missions for ASEAN or participating on behalf of Member States in connection with official ASEAN activities;

(c) inviolability for all papers and documents;

(d) for the purpose of their communications with ASEAN, the right to use codes and to receive papers or correspondence by courier or in sealed bags;

(e) the same facilities in respect of currency or exchange restrictions as are accorded to representatives of foreign governments on temporary official missions;

(f) the same immunities and facilities in respect of their personal baggage as are accorded to diplomatic envoys.

2. Privileges and immunities are granted to experts in the interests of ASEAN and not for the personal benefit of the individuals themselves. The Secretary-General of ASEAN shall have the right and the duty to waive the immunity of any expert in any case where, in his or her opinion, the immunity would impede the course of justice and it can be waived without prejudice to the interests of ASEAN.



CERTIFIED COPY DEPUTY SECRETARY-GENERAL OF ASEAN

3. Before the commencement of missions of such experts on missions for ASEAN, the Secretary-General of ASEAN shall:

(a) send a notification to the ASEAN National Secretariat of the Member State concerned in which they are performing their missions, the names of the appointed experts on missions for ASEAN, the nature of their missions and the length of their stay; and

(b) issue documents of identification, if necessary, for such appointed experts on missions for ASEAN.

**Article 6**
**Permanent Mission**

The relevant provisions on privileges and immunities relating to diplomatic missions in the Vienna Convention shall apply *mutatis mutandis* to the Permanent Mission.

**Article 7**
**Permanent Representatives and Officials on ASEAN Duties**

1. The relevant provisions in the Vienna Convention relating to privileges and immunities for diplomatic agents and members of their families forming part of their households shall apply *mutatis mutandis* to the Permanent Representatives and officials on ASEAN duties and members of their families while they are in the host Member State.

2. The provisions on privileges and immunities relating to the officials of the Member States under Article 9 of this Agreement shall apply *mutatis mutandis* to the Permanent Representatives and officials on ASEAN duties while they participate in official





CERTIFIED DEPUTY SECRETARY-GENERAL asean

ASEAN activities or represent ASEAN in Member States, other than the host Member State.

3. Privileges and immunities are accorded to the Permanent Representatives and officials on ASEAN duties in order to safeguard the independent exercise of their functions in connection with ASEAN and not for the personal benefit of the individuals themselves. Consequently, a Member State not only has the right but is under a duty to waive the immunity of its Permanent Representative and officials on ASEAN duties in any case where in the opinion of that Member State the immunity would impede the course of justice, and it can be waived without prejudice to the purposes for which the immunity is accorded.

**Article 8**
**Staff of the Permanent Mission**

២-ក្រសួងព័ត៌មានត្រូវណែនាំឱ្យប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជន ផ្សព្វផ្សាយសារលិខិតរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងឱកាសខួបលើកទី៧នៃទិវាអតីតយុទ្ធជនកម្ពុជា ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៤ និងខ្លឹមសារឯកសារនានាពាក់ព័ន្ធនឹងទិវាអតីតយុទ្ធជនកម្ពុជា ក៏ដូចជាសកម្មភាពសង្គមរបស់អតីតយុទ្ធជនកម្ពុជា។

៣-អាជ្ញាធរដែនដីរាជធានី ខេត្ត ត្រូវសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា នៅរាជធានី ខេត្តនីមួយៗ ដើម្បីរៀបចំពិធីសំណេះសំណាលជាមួយអតីតយុទ្ធជន និងរៀបចំទិវាអតីតយុទ្ធជនកម្ពុជាលើកទី៧ នៅតាមរាជធានី ខេត្ត។ ៚

៤-គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគណៈប្រតិភូចុះសួរសុខទុក្ខអតីតយុទ្ធជនតាមមូលដ្ឋាន និងយុទ្ធជន យុទ្ធនារីដែលកំពុងបំពេញបេសកកម្មនៅតំបន់ព្រំដែន យុទ្ធជន យុទ្ធនារីដែលកំពុងសម្រាកព្យាបាលតាមមន្ទីរពេទ្យ និងជនពិការនៅតាមមណ្ឌលយុទ្ធជនពិការ ដើម្បីផ្សារភ្ជាប់មនោសញ្ចេតនា និងលើកទឹកចិត្តដល់អតីតយុទ្ធជន និងយុទ្ធជន យុទ្ធនារី។

៥-គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរទិវាអតីតយុទ្ធជនកម្ពុជា លើកទី៧ ២១ មិថុនា ២០១៤
- រៀនសូត្រតាមគំរូវីរភាពរបស់អតីតយុទ្ធជនកម្ពុជា
- អភិវឌ្ឍអតីតយុទ្ធជន ដើម្បីអភិវឌ្ឍប្រទេសជាតិ និងការពារមាតុភូមិ
- ការពារជាតិដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការពារជាតិ។

៦-រាជរដ្ឋាភិបាល សូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន មន្ត្រីរាជការ អតីតយុទ្ធជន និងយុទ្ធជន យុទ្ធនារីនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងបងប្អូនជនរួមជាតិ ព្រមទាំងដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ផ្នែកឯកជនទាំងអស់ សូមចូលរួមអបអរសាទរទិវាអតីតយុទ្ធជនកម្ពុជាលើកទី៧ ក្នុងសេចក្តីសោមនស្សរីករាយ ដោយប្រែក្លាយទិវានេះឱ្យទៅជាមហាចលនាសាមគ្គីភាព ជួយឧបត្ថម្ភគាំទ្រ និងផ្សារភ្ជាប់ជាមួយអតីតយុទ្ធជន ដែលមានគុណបំណាច់ចំពោះជាតិមាតុភូមិ ក៏ដូចជាយុទ្ធជន យុទ្ធនារីដែលកំពុងបំពេញបេសកកម្មនៅតំបន់ព្រំដែនដើម្បីការពារបូរណភាពទឹកដីមាតុភូមិអង្គរដ៏បវររបស់យើង។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មិថុនា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:..០៦..សរ....**

## សារាចរ
## ស្តីពី
## ការរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា

ទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ត្រូវបានរៀបចំស្របតាមគោលនយោបាយជាតិសម្រាប់មនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។ ការប្រារព្ធទិវានេះ មានគោលបំណងលើកកម្ពស់កិច្ចគាំពារដ៏មានប្រសិទ្ធភាព សំដៅលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ឱ្យកាន់តែប្រសើរឡើង ហើយទិវានេះក៏បង្ហាញឱ្យឃើញអំពីតួនាទីដ៏សំខាន់របស់មនុស្សចាស់ បុព្វការីជន ដែលបានបង្កើតធនធានដ៏មានសារៈប្រយោជន៍ ព្រមទាំងផ្តល់នូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធន៍យ៉ាងច្រើនឥតគណនាសម្រាប់មនុស្សជំនាន់ក្រោយ។ ក្នុងគោលបំណងយកចិត្តទុកដាក់ខ្ពស់ចំពោះមនុស្សចាស់កម្ពុជា រាជរដ្ឋាភិបាលបានបង្កើតឱ្យមានគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ដើម្បីអនុវត្តនូវតួនាទី និងភារកិច្ចដែលមានជាអាទិ៍ រៀបចំគោលនយោបាយជាតិ ដើម្បីលើកស្ទួយសុខុមាលភាពរបស់មនុស្សចាស់ និងរៀបចំទិវាមនុស្សចាស់នៃព្រះរាជាណាចក្រកម្ពុជា ដោយកំណត់យកថ្ងៃទី០១ ខែតុលា ជារៀងរាល់ឆ្នាំ រួមជាមួយទិវាមនុស្សចាស់អន្តរជាតិ។

រាជរដ្ឋាភិបាលចាត់ទុកទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ជាទិវាបុណ្យរម្លឹកដល់គុណូបការៈរបស់មនុស្សចាស់កម្ពុជា បុព្វការីជន ជីដូន ជីតា ឪពុក ម្តាយ អ៊ុំ ពូ មីង ដែលបានកសាង និងបន្សល់ទុកនូវកេរមរតកដ៏ថ្លៃថ្លាសម្រាប់កូនចៅជំនាន់នេះ និងជំនាន់ក្រោយៗទៀត។ ដើម្បីរៀបចំទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ឱ្យបានទូលំទូលាយ និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូប បានយល់ដឹងកាន់តែច្បាស់អំពីអត្ថន័យនៃទិវានេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចតទៅ ៖

១- ប្រធានបទនៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ត្រូវបានកំណត់ថា "សមាគមមនុស្សចាស់ជាយន្តការដ៏សំខាន់ ជួយអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិ"។៨

២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ត្រូវសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិ ដែលពាក់ព័ន្ធដើម្បីចាត់តាំងមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ ឱ្យបានអធិកអធម។

៣- រាជធានី ខេត្ត ត្រូវរៀបចំមិទ្ទិញអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៤ ដោយបង្កលក្ខណៈឱ្យមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ព្រះសង្ឃ បព្វជិត លោកយាយ លោកតា ព្រមទាំងប្រជាជនគ្រប់វ័យបានចូលរួម ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែទូលំទូលាយអំពីសារៈសំខាន់នៃគោលនយោបាយជាតិ ចំពោះមនុស្សចាស់កម្ពុជា។

៤- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ សូមបន្តជួយគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍សមាគមមនុស្សចាស់ដែលមានស្រាប់ និងបង្កើតបន្ថែមទៀត នៅតាមសហគមន៍មូលដ្ឋាននៅគ្រប់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវបង្កើនការយកចិត្តទុកដាក់អនុវត្តតាមការណែនាំ និងបង្កើតឱ្យមានសមាគមមនុស្សចាស់ក្នុងមូលដ្ឋានគ្រប់ឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើនស្មារតីសាមគ្គីភាពជួយគ្នាទៅវិញទៅមក រវាងមនុស្សចាស់ទូទៅ ជាពិសេសយកចិត្តទុកដាក់ជួយជនចាស់ជរា ពិការ ក្រីក្រទុរគត។

៥- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំកម្មវិធីចុះសំណេះសំណាលជាមួយមនុស្សចាស់ នៅតាមមូលដ្ឋាន វត្តអារាម វិហារសាសនានានា ដោយនាំយកជំនួយឧបត្ថម្ភតាមសទ្ធាជ្រះថ្លា ជួយដល់មនុស្សចាស់ជរា ពិការ ក្រីក្រទុរគត។

៦- ក្រសួងធម្មការ និងសាសនា ត្រូវធ្វើការណែនាំនិងចលនានៅតាមវត្តអារាម វិហារសាសនាទូទាំងប្រទេសតាមរយៈបព្វជិតសាសនា ដើម្បីឱ្យមានសកម្មភាពជួយឧបត្ថម្ភគាំទ្រដល់ជនចាស់ជរា ពិការ ក្រីក្រទុរគត។

៧- ក្រសួងព័ត៌មាន ត្រូវណែនាំបណ្តាញព័ត៌មានរដ្ឋ និងឯកជនទាំងអស់ ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវខ្លឹមសារនិងសកម្មភាពនៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤។

៨- គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំបដានៅតាមអង្គភាព និងទីសាធារណៈតាមខ្លឹមសារ ដូចតទៅ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា !
- អបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ ០១ តុលា
- មនុស្សចាស់ជាមរតកដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និងសង្គមជាតិ
- គោរពដឹងគុណចំពោះមនុស្សចាស់ គឺជាកតញ្ញូតាធម៌ គ្រួសារមានសុភមង្គល សង្គមរីកចម្រើន
- កសាងសង្គមដែលមានការអភិវឌ្ឍសម្រាប់មនុស្សគ្រប់វ័យ
- សមាគមមនុស្សចាស់ជាយន្តការដ៏សំខាន់ ជួយអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិ។៚

៩- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវធ្វើការណែនាំអនុវត្តតាមសារាចរនេះ និងបូកសរុបលទ្ធផលការងារជូនរាជរដ្ឋាភិបាល។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៥ សរណន

# សារាចរណែនាំ

## ស្តីពីការចូលរួមគោរពព្រះវិញ្ញាណក្ខ័ន្ធ និងដង្ហែព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ “ ព្រះករុណា ព្រះបរមរតនកោដ្ឋ ”

ព្រះរាជពិធីដង្ហែ **ព្រះបរមអដ្ឋិ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ “ ព្រះករុណា ព្រះបរមរតនកោដ្ឋ ”** នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី ១០-១១ និង ១២ ខែ កក្កដា ឆ្នាំ ២០១៤ ។

ដើម្បីមានឱកាសចូលរួមសំដែងការគោរពព្រះវិញ្ញាណក្ខ័ន្ធ និងដង្ហែ **ព្រះបរមអដ្ឋិ ព្រះករុណា ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញសារាចរណែនាំដូចតទៅ :

១- អនុញ្ញាតឱ្យមន្ត្រីរាជការ បុគ្គលិក និយោជិត កម្មករ បានឈប់សម្រាករយៈពេល ០១ ថ្ងៃ គឺនៅថ្ងៃសុក្រ ទី ១១ ខែ កក្កដា ឆ្នាំ ២០១៤ ដើម្បីចូលរួមសំដែងគោរពព្រះវិញ្ញាណក្ខ័ន្ធ និងដង្ហែ **ព្រះបរមអដ្ឋិ** ។

២- គ្រប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ជាតិ និងឯកជន ព្រមទាំងកន្លែងកំសាន្តសប្បាយ ត្រូវផ្អាកការផ្សាយនូវទស្សនីយភាពការសម្តែង និងការប្រគុំតន្ត្រីផ្សេងៗ ដែលមានលក្ខណៈសប្បាយគគ្រឹកគគ្រេង ក្នុងថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៤ ជាថ្ងៃប្រារព្ធព្រះរាជពិធីដង្ហែ **ព្រះបរមអដ្ឋិ** ។

៣- គ្រឹះស្ថាន អគារសាធារណៈ អគារលក់ដូរគ្រប់ប្រភេទតាមដងផ្លូវដង្ហែ ដែលនៅតាមបណ្តោយវិថីសម្តេចព្រះធម្មលិខិតអ៊ុក.មហាវិថីព្រះនរោត្តម.វិថីព្រះសីហនុ.វិថីសម្តេចសុធារស ត្រូវបញ្ឈប់សកម្មភាពការងារ និងលក់ដូរ នៅថ្ងៃសុក្រ ទី ១១ ខែ កក្កដា ឆ្នាំ ២០១៤ ដើម្បីសម្រួលដល់ការងារចរាចរ ។

៤- រាជធានីភ្នំពេញ គ្រប់ខេត្ត  គ្រប់ទីប្រជុំជន  និងគ្រប់វត្តអារាមក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់តាំង ដោតទង់ជាតិ ទង់សាសនា ទង់ផ្កាលា ប្រារព្ធពិធីបុណ្យតាមប្រពៃណី  ដើម្បីថ្វាយព្រះរាជកុសល និង គោរពព្រះវិញ្ញាណក្ខន្ធ **ព្រះគរុណា ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទៅតាម ប្រពៃណី មានប្រគំភ្លេងពិណពាទ្យ វាយគង ទូងស្គរ ទៅតាមកម្មវិធីកំណត់ អោយបានស័ក្តិសម នឹង ព្រះរាជគុណូបការ ដ៏ធំធេងរបស់ព្រះអង្គ  ចំពោះ  ជាតិ  សាសនា  និងប្រជានុរាស្ត្រកម្ពុជា ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន គ្រប់អាជ្ញាធរមានសមត្ថកិច្ច  អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ គ្រប់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ  ព្រមទាំងជនរួមជាតិ  ប្រជាជនទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមអនុវត្តសារាចរនេះអោយមានប្រសិទ្ធភាពខ្ពស់  ដើម្បីជាកិច្ចចូលរួមសំដែងការគោរពដ៏ជ្រាលជ្រៅ ចំពោះ **ព្រះគរុណា  ព្រះបរមរតនកោដ្ឋ**  ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

*រាជធានីភ្នំពេញ, ថ្ងៃទី  ១២  ខែ  មិថុនា  ឆ្នាំ២០១៤*

សម្ដេចអគ្គមហាសេនាបតីតេជោ  ហ៊ុន  សែន

<u>**កន្លែងទទួល**</u> **:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការ និង គ្រប់អនុគណៈកម្មការរៀបចំ ព្រះរាជពិធីបុណ្យដង្ហែ ព្រះបរមអដ្ឋិ

" ដើម្បីជូនជ្រាប "

- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ [illegible] សហវ.[illegible]

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៩៨ អនក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664    Fax: 855-23-427 798

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ជុំ ទិចិត្ត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. ឯកឧត្តម | **សរ សុវណ្ណា** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៣. លោកជំទាវ | **ម៉ុម ថានី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ជាអនុប្រធាន |
| ៤. ឯកឧត្តម | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាអនុប្រធានប្រចាំការ |
| ៥. ឯកឧត្តម | **នេត មុន្នី** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៦. ឯកឧត្តម | **ហេង សុខណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧. ឯកឧត្តម | **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៨. លោក | **រស់ តិរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៩. លោក | **អោម ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ១០. កញ្ញា | **ឈឺន សុគន្ធា** | មន្ត្រីនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាលេខាធិការ |
| ១១. កញ្ញា | **ស៊ីន សុខពៅ** | មន្ត្រីនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាលេខាធិការ |

**ប្រការ ២.-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានភារកិច្ច ដូចខាងក្រោម ÷

- បង្កើតបញ្ជីវាយនាមឈ្មោះតំបន់ ឬខណ្ឌ នៃរាជធានី និងក្រុង ស្រុក នៃខេត្ត ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុងមួយម៉ែត្រក្រឡា
- ផ្ដល់មតិចំពោះរឿងវិវាទ។

**ប្រការ ៣.-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានសិទ្ធិចាត់តាំងអនុគណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅតាមរាជធានី-ខេត្ត ដែលមានអភិបាលរាជធានី-ខេត្ត ឬតំណាងជាប្រធាន សម្រាប់ជំនួយការក្នុងការអនុវត្តភារកិច្ចខាងលើ។

**ប្រការ ៤.-**

គណៈកម្មការវាយតម្លៃដី សម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញការងារ និងភារកិច្ចរបស់ខ្លួន។

**ប្រការ ៥.-**

ប្រកាសលេខ ០៦៧ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

សមាសភាពដូចមានរាយនាមក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន ÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- សាលារាជធានី-ខេត្ត "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ១ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......៦៤៩..........សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើត គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "កសហវ" ដែលសរសេរជាអក្សរកាត់ថា "**គ.ក.ហ.**" ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.-**

**គ.ក.ហ.** មានសមាសភាពដូចតទៅ ÷

| | | | |
|---|---|---|---|
| ១. រដ្ឋមន្ត្រី | កសហវ | | ប្រធាន |
| ២. រដ្ឋលេខាធិការ | កសហវ | ១ រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. រដ្ឋលេខាធិការ | កសហវ | ផ្សេងទៀត | អនុប្រធាន |
| ៤. អគ្គលេខាធិការ | អ.គ.ហ | | អនុប្រធានប្រចាំការ |
| ៥. អនុរដ្ឋលេខាធិការ | កសហវ | | សមាជិក |
| ៦. អគ្គលេខាធិការ | កសហវ | | សមាជិក |
| ៧. អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន | កសហវ | | សមាជិក |
| ៨. អគ្គាធិការនៃអគ្គាធិការដ្ឋាន | កសហវ | | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ក.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

**គ.ក.ហ.** មានមុខងារនិងភារកិច្ចដូចតទៅ÷

- ធ្វើជាចំណុចប្រមូលផ្តុំរបស់ កសហវ ក្នុងការរៀបចំនិងតាមដានការអនុវត្តផែនការសកម្មភាពរបស់ កសហវ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលការងារកែទម្រង់នេះ ជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ រួមទាំងរាជធានី ខេត្ត
- ពិនិត្យនិងសម្រេចលើចក្ខុវិស័យ គោលបំណង កម្មវិធី និងផែនការសកម្មភាព របស់ កសហវ ក្នុងក្របខណ្ឌការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ
- ដឹកនាំនិងតាមដានការអនុវត្តចក្ខុវិស័យ គោលបំណង កម្មវិធី និងផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធានាឱ្យបាននូវសង្គតិភាព លំដាប់លំដោយត្រឹមត្រូវ និងប្រសិទ្ធភាពខ្ពស់ នៅក្នុងកិច្ចដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ
- សម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ ជាមួយការងារកែទម្រង់ផ្សេងទៀតរបស់ រាជរដ្ឋាភិបាល
- ធ្វើជាចំនុចប្រមូលផ្តុំរបស់ កសហវ ក្នុងការកៀរគរជំនួយនិងការសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ កសហវ ជាមួយដៃគូអភិវឌ្ឍន៍នានា។

**ប្រការ៤.-**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាននិងសមាជិក **គ.ក.ហ** ត្រូវចូលរួមប្រជុំសាមញ្ញរបស់ខ្លួនក្នុងមួយខែមួយដង ឬញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ។

ប្រធាន **គ.ក.ហ** អាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនានានៃ កសហវ ដែលមិនមែនជាសមាជិកនៃ **គ.ក.ហ.** ឱ្យចូលរួមប្រជុំ ទៅតាមតម្រូវការចាំបាច់នៃការងារ។

**ប្រការ៥.-**

ក្នុងករណីអវត្តមាន សមាជិកនៃ **គ.ក.ហ** ដែលជាអគ្គលេខាធិការ អគ្គនាយក ឬអគ្គាធិការ អាចស្នើសុំការអនុញ្ញាតពីប្រធាន **គ.ក.ហ** ដើម្បីចាត់តាំងអគ្គលេខាធិការរង អគ្គនាយករង ឬអគ្គាធិការរងមួយរូបឱ្យចូលរួមប្រជុំជំនួស។

សមាជិក **គ.ក.ហ** អាចស្នើសុំការអនុញ្ញាតពីប្រធាន **គ.ក.ហ** ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារកែទម្រង់ នៅក្នុងអង្គភាពរបស់ខ្លួន ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ។

**ប្រការ៦.-**

**គ.ក.ហ** មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសេនាធិការបច្ចេកទេសរបស់ខ្លួន ក្នុងការបំពេញការងារ។

**ប្រការ៧.-**

**គ.ក.ហ** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៨.-**

ត្រូវបាននិរាករ ដូចតទៅ÷

- ប្រកាសលេខ ៤៥១ សហវ.ប្រក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ០៣៦ សហវ.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើតអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៣៥ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមសម្របសម្រួល នៃក្រសួង ស្ថាប័ន
- សេចក្តីសម្រេចលេខ ០៣៤ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៣៣ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស
- ប្រកាសលេខ ១២០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ប្រកាសលេខ ១៥០ សហវ.ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអនុគណៈកម្មាធិការសម្រាប់ជំរុញការអនុវត្តការងារក្នុងក្របខណ្ឌគម្រោងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យា
- ប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមការងាររៀបចំមាតិកាគណនេយ្យនិងថវិកាថ្មី
- ប្រកាសលេខ ២៩០ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតអនុគណៈកម្មាធិការជ្រើសរើសនិងផ្តល់ការលើកទឹកចិត្ត នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកម្មវិធីកន្សោមអាទិភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ៥៨៨ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការផ្ទេរមុខងារបន្ថែមឱ្យទៅអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រកាសលេខ ៥៩២សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់
- ប្រកាសលេខ ២២៥សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៣ សហវ.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេច

# ស្តីពី

# ការតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- ប្រកាសលេខ      សហវ.ប្រក ចុះថ្ងៃទី      ខែ      ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.–**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្ដម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រី កសហវ | ប្រធាន |
| ២. ឯកឧត្ដម **វង្សី វិស្សុត** | រដ្ឋលេខាធិការ កសហវ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្ដម **ជូ វិជិត្ត** | រដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៤. លោកជំទាវ **ខូន សុខា** | រដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៥. ឯកឧត្ដម **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៦. ឯកឧត្ដម **ងី តាយី** | រដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៧. ឯកឧត្ដម **ជូ គីមឡេង** | រដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៨. ឯកឧត្ដម **សុខ សារាវុឌ្ឍ** | អគ្គលេខាធិការ អ.ត.ហ | អនុប្រធានប្រចាំការ |
| ៩. ឯកឧត្ដម **ញាណ ឡៀង** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១០. ឯកឧត្ដម **សួន ម៉េងកា** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១១. ឯកឧត្ដម **ឆាន់ វឌ្ឍនៈ** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១២. ឯកឧត្ដម **រស់ សីលវ៉ា** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១៣. លោកជំទាវ **កែវ ចរិយា** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១៤. ឯកឧត្ដម **វង់ សណ្ដាប់** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១៥. ឯកឧត្ដម **ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១៦. ឯកឧត្ដម **ឈន សុភាព** | អនុរដ្ឋលេខាធិការ កសហវ | សមាជិក |
| ១៧. ឯកឧត្ដម **ហ៊ីវ សុវណ្ណា** | អគ្គលេខាធិការ កសហវ | សមាជិក |
| ១៨. ឯកឧត្ដម **ម៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ១៩. ឯកឧត្ដម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ២០. ឯកឧត្ដម **ផាន់ ផល្លា** | អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ២១. ឯកឧត្ដម **ចាន់ សុធី** | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |

| | | |
|---|---|---|
| ២២. ឯកឧត្តម **កែវ ម៉េងឡុន** | អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ២៣. ឯកឧត្តម **ឈឹម សារ៉ែត** | អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ២៤. ឯកឧត្តម **នេត មុន្នី** | អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ២៥. ឯកឧត្តម **ខេង ម៉ិនឥន្ទ្រាធុន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ២៦. ឯកឧត្តម **ម៉ី ទ៉ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ២៧. ឯកឧត្តម **ឯក ទីរដេដ្ឋ** | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ២៨. ឯកឧត្តម **ជា ទុនណា** | អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក។ |

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៤

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៣៤៧ ឧស.ក.ក-ប្រក-

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-យោងលិខិតលេខ ៧៤៣/១៤ គ.វ.ក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យូនីខន (ខេមបូឌា) រីគ្រីអេសិន ប្រូដាក់ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤

## <u>ស ម្រេ ច</u>

**<u>ប្រការ១៖</u>** អនុញ្ញាតឲ្យក្រុមហ៊ុន យូនីខន (ខេមបូឌា) រីគ្រីអេសិន ប្រូដាក់ (UNICORN (CAMBODIA) RECREATION PRODUCTS CO., LTD.) តំណាងដោយ លោក CAI SIKUI សញ្ជាតិចិន អាយុ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G32779011 ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ No. 12-2-502, Anhuali, Binshuixi Road, Nankai District, Tianjin, China. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រកាត់ដេរសម្លៀកបំពាក់ យូនីខន (ខេមបូឌា) រីគ្រីអេសិន ប្រូដាក់"*

**ទីតាំងរោងចក្រ ៖** *"ផ្លូវជាតិលេខ២ ភូមិកណ្តាល សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុង ប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការ រោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុង ប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួល ទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៣.៩៦...ឧស.ក.ឧ.ឧ.ប.ក.

# ប្រកាស
## ស្ដីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-យោងលិខិតលេខ ១៩៤/១៤ គ.វ.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អ៊ីសធើន អង្គរ អ៊ីនវេសមិន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ីសធើន អង្គរ អ៊ីនវេសមិន (EASTERN ANGKOR INVESTMENT CO., LTD.) តំណាងដោយ លោក ស្រេង ចាន់ធី សញ្ជាតិខ្មែរ អាយុ៤២ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០១៦៩៥០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ មានអាសយដ្ឋានបច្ចុប្បន្ន៖ លេខ២៥អា ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១.ប្រដាប់ព្យួរសម្លៀកបំពាក់ (ពីប្លាស្ទិក) | ២២២០ |
| ២.ប្រដាប់ព្យួរសម្លៀកបំពាក់ (ពីដែក) | ២៥៩៩ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រផលិតប្រដាប់ព្យួរសម្លៀកបំពាក់គ្រប់ប្រភេទ អ៊ីសផើន អង្គរ អ៊ីនវេសម៉ិន"*

**ទីតាំងរោងចក្រ ៖** *"ភូមិបាគូ សង្កាត់ជជោ ខណ្ឌជជោ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញនៅពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹង ត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់ កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ